**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំពិភាក្សារវាងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ជាមួយនឹងក្រសួងព័ត៌មាន នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ នៅវិមានរដ្ឋសភា ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា បានដឹកនាំប្រតិភូគណៈកម្មការទី៥ និងតំណាងគណៈកម្មការពាក់ព័ន្ធ ជួបប្រជុំជាមួយ ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងសហការី ដើម្បីស្វែងយល់ពី **"កិច្ចការប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា"**។ កិច្ចប្រជុំនេះរៀបចំឡើងអនុលោមតាមរដ្ឋធម្មនុញ្ញ មាត្រា៩៧ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាប្រការ៣៤ថ្មី និងសេចក្តីសម្រេចលេខ ០០៥រស ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា។

ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥នៃរដ្ឋសភា បានមានប្រសាសន៍ស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះជំនួបពិភាក្សានាពេលនេះ ដោយបានចាត់ទុកថា កិច្ចប្រជុំនាពេលនេះ គឺជាការពិគ្រោះយោបល់រវាងគណៈកម្មការជំនាញរដ្ឋសភា ជាមួយក្រសួងព័ត៌មាន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធសារព័ត៌មាននៅកម្ពុជា សំដៅលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ និងជម្រុញកិច្ចសហការជាមួយក្រសួងព័ត៌មានក្នុងការផ្សព្វផ្សាយអំពីកិច្ចការសភា និងកិច្ចការរបស់តំណាងរាស្ត្រជូនសាធារណជន ឱ្យកាន់តែទូលំទូលាយ។

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានមានប្រសាសន៍ជម្រាបជូន អំពីការវិវឌ្ឍរីកចម្រើននៃវិស័យព័ត៌មាន ក្នុងបរិបទនៃសម័យបច្ចេកវិទ្យាទំនើប ដែលធ្វើឱ្យស្ថាប័នផ្សព្វផ្សាយព័ត៌មានទាំងសាធារណៈ និងឯកជននៅកម្ពុជា មានការកើនឡើងច្រើនទាំងកាសែត វិទ្យុ ទូរទស្សន៍ និងបណ្តាញផ្សព្វផ្សាយអនឡាញជាដើម។ ភាពរីកចម្រើននេះក៏នឹងនាំឱ្យក្រសួងគិតគូរពីការធ្វើបច្ចុប្បន្នភាពលើច្បាប់ស្តីពីរបបសារព័ត៌មាននៅពេលខាងមុខ ដើម្បីឱ្យសមស្របទៅនឹងបរិបទជាក់ស្តែងនៃសង្គមជាតិ។

**ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានជម្រាបជូនថា ក្រសួងកំពុងដំណើរការរៀបចំ ទម្រង់ឌីជីថល ដែលអាចឱ្យស្ថានីយទូរទស្សន៍ឯកជនទាំងអស់នៅកម្ពុជា ជួលសេវាកម្មនេះក្នុងការផ្សព្វផ្សាយស្ថានីយរបស់ខ្លួនបានគ្របដណ្តប់ពេញទូទាំងប្រទេស។

ភាគីទាំងពីរក៏បានលើកឡើងអំពីសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលច្បាប់នេះគឺជាច្បាប់ដ៏សំខាន់ មានភាពស្មុគស្មាញ និងមានការពាក់ព័ន្ធក្រសួងស្ថាប័នជាច្រើនដែលត្រូវធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ ហើយបច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះ ស្ថិតនៅក្រសួងយុត្តិធម៌ កំពុងពិនិត្យមើលលើជំពូកស្តីពីទោសប្បញ្ញត្តិ និងមានគម្រោងសម្រេចចេញឱ្យបាននៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា នាពេលខាងមុខនេះ។

គណៈកម្មការរដ្ឋសភា និងក្រសួងព័ត៌មាន បានយល់ស្របគ្នាថា ព័ត៌មានមានសារសំខាន់បំផុត សម្រាប់ការដឹកនាំនៅក្នុងសតវត្សថ្មី។ «ការផ្សព្វផ្សាយព័ត៌មានល្អគឺជួយសង្គម ការផ្សព្វផ្សាយព័ត៌មានមិនល្អគឺជាការជាន់ពន្លិចសង្គម»ភាគីទាំងពីរក៏បានកោតសរសើរចំពោះអ្នកសារព័ត៌មានទាំងអស់នៅកម្ពុជាដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ១៩ នៅក្នុងការងារគ្រប់គ្រងព័ត៌មានមិនពិត និងបានចូលរួមផ្សព្វផ្សាយព័ត៌មានច្បាស់លាស់អំពីបញ្ហាជំងឺកូវីដ១៩ ដោយបានធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹង ចូលរួមក្នុងការចាក់វ៉ាក់សាំងរហូតដល់ដូសទីបី បានជាង១០លាននាក់ ដែលអាចឱ្យយើងគ្រប់គ្រងស្ថានការណ៍បាន និងបើកដំណើរការប្រទេសឡើងវិញបានដោយសុវត្ថិភាព។

រដ្ឋសភាបានលើកជាសំណូមពរដល់ក្រសួងព័ត៌មាន ធ្វើការសិក្សាពិនិត្យលទ្ធភាពក្នុងការបង្កើតកម្មវិធីទូរទស្សន៍របស់សភាដាច់ដោយឡែក ក្នុងគោលបំណងផ្សព្វផ្សាយទៅកាន់សាធារណជនឱ្យបានជ្រួតជ្រាបនូវកិច្ចការងារសភាជាពិសេសក្នុងក្របខណ្ឌក្រុមសមាជិកសភាវ័យក្មេងក្នុងភាពជាតំណាងរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។ ភាគីទាំងពីរ ក៏បានលើកឡើងនូវគំរូជាឧទាហរណ៍ អំពីប៉ុស្តិ៍ទូរទស្សន៍សភានៃបណ្តាប្រទេសជឿនលឿនមួយចំនួនទាំងនៅអាស៊ី និងអឺរ៉ុប។ រដ្ឋសភាក៏បានស្នើដល់ក្រសួងព័ត៌មាន ធ្វើការពិចារណា ក្នុងការផ្តល់មេដាយឆ្នើម ជូនអ្នកសារព័ត៌មានកម្ពុជាណាដែលបានការទទួលស្គាល់នូវគុណតម្លៃពីរដ្ឋសភា និងបានជ្រើសរើស ក្រោមការពិនិត្យវាយតម្លៃអំពីគុណសម្បត្តិនិងការខិតខំបំពេញការងារទៅតាមវិជ្ជាជីវៈរបស់ខ្លួន ដោយក្រសួងព័ត៌មាន។

ភាគីទាំងពីរបានឯកភាពបន្តកិច្ចសហការគ្នាបន្ថែមទៀត លើការងារផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាព ដល់សាធារណជន និងរួមគ្នារវាងក្រសួងនិងរដ្ឋសភាដើម្បីការពារធម្មានុរូបនៃលទ្ធផលបោះឆ្នោតនាពេលខាងមុខ ក៏ដូចជាការជម្រុញការផ្សព្វផ្សាយព័ត៌មានអំពីសភា ការអប់រំច្បាប់ និងភាពសុខដុមរមនាផ្នែកសាសនានៅកម្ពុជាជាដើម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាប៕

ថ្ងៃពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**